**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៣៥៨ ព.ណ.អ.វ.ស

ថ្ងៃចន្ទ ១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ដល់៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នឹងត្រូវលក់៣.០៧៩រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៧៦៨រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី១៦ ដល់៣០ ខែវិច្ឆិកា ឆ្នាំ២០២០** នឹងចុះមក២.៩០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៦០០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | ០,២៧៤២ដុល្លារ | ០,២៨១២ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៧៩១ ដុល្លារ | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | ០,០២៩៦ ដុល្លារ |
| ៣ | PREMIUM | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៦៥៣ ដុល្លារ | ០,០៥៨១ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៧១៨៦ ដុល្លារ | ០,៦៣៨៩ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ២.៩១៦ រៀល | ២.៥៩៣ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៧២ ដុល្លារ | ០,៦៤ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ២.៩០០ រៀល | ២.៦០០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលស្មើនឹង៤០៥៨រៀល/ដុល្លារអាមេរិក

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង DO 0.05% (USD/Barrel) |
|---|---|---|
| ២ វិច្ឆិកា ២០២០ | ៣៨,៨៥ | ៣៩,០៥ |
| ៣ វិច្ឆិកា ២០២០ | ៤២,០០ | ៤២,៥៨ |
| ៤ វិច្ឆិកា ២០២០ | ៤១,៩៤ | ៤២,៧៣ |
| ៥ វិច្ឆិកា ២០២០ | ៤៣,២៥ | ៤៤,០០ |
| ៦ វិច្ឆិកា ២០២០ | ៤៣,១៥ | ៤៣,៦៣ |
| ៩ វិច្ឆិកា ២០២០ | ៤២,៨៣ | ៤៣,៧៧ |
| ១០ វិច្ឆិកា ២០២០ | ៤៥,២៩ | ៤៧,០១ |
| ១១ វិច្ឆិកា ២០២០ | ៤៧,៥៥ | ៤៩,២០ |
| ១២ វិច្ឆិកា ២០២០ | ៤៦,១៦ | ៤៨,១០ |
| ១៣ វិច្ឆិកា ២០២០ | ៤៤,៩៥ | ៤៧,០៥ |
| **មធ្យមភាគ១០ថ្ងៃ** | **៤៣,៥៩៧០** | **៤៤,៧១២០** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,២៧៤២** | **០,២៨១២** |

**ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ខែកញ្ញា ដល់ ១៦ ខែវិច្ឆិកា ឆ្នាំ២០២០**




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម